# សុន្ទរកថា

# ឯកឧត្តម អៀង មូលី នៅក្នុងកិច្ចប្រជុំសម្របសម្រួលជាន់ខ្ពស់ ស្តីពីការអនុវត្តន៍បទអន្តរាគមន៍បង្ការមេរោគអេដស៍ និង ជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស

**ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣   នៅសណ្ឋាគារសាន់វេ**

- ឯកឧត្តមអគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- លោកជំទាវ ម៉ក់ វណ្ណស៊ីថា អភិបាលរងរាជធានីភ្នំពេញ និង ជាប្រធានគណៈកម្មាការអេដស៍រាជធានីភ្នំពេញ
- ឯកឧត្តម - លោកជំទាវ
- លោក លោកស្រី និង តំណាង អង្គការជាតិ និង អន្តរជាតិ
- លោក លោកស្រី ប្អូនៗ ក្មួយៗ ដែលក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ជាទីមេត្រី !

ក្នុងឱកាសនេះ ខ្ញុំមានសេចក្តីសោមនស្ស រីករាយ ដែលបានចូលរួមធ្វើជាអធិបតី និងដែលមានឱកាសថ្លែងសុន្ទរកថាបើកនៃ" ***កិច្ចប្រជុំជាន់ខ្ពស់ ស្តីពីការអនុវត្តន៍ បទអន្តរាគមន៍បង្ការមេរោគអេដស៍ និង ជំងឺ អេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់*** " ។ ក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះការរៀបចំនូវកិច្ចប្រជុំនេះឡើង តាមរយៈកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង អង្គការសេវាសង្គមសុខភាពបុរស ដោយមានការឧបត្ថម្ភថវិកាពី USAID តាមរយៈ គម្រោង Flagship និង សូមថ្លែងអំណរគុណចំពោះ លោក លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនេះទាំងមូល ។

តាមរយៈការអនុវត្តន៍ការងារកន្លងមក ប្រទេសកម្ពុជាបានទទួលជោគជ័យយ៉ាងធំធេង ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និង ជំងឺអេដស៍នាពេលកន្លងទៅ ដោយអត្រានៃការឆ្លង បានធ្លាក់

ចុះពី ១.៧% ក្នុងឆ្នាំ ១៩៩៨ មកនៅត្រឹម ០.៧ ក្នុងឆ្នាំ ២០១៣ នេះ ។ តែជាមួយនឹងជោគជ័យនេះ យើងទាំងអស់គ្នា ត្រូវកុំភ្លេចថា បញ្ហាមេរោគអេដស៍ និង ជំងឺអេដស៍នេះ នៅបន្តរីករាលដាលដល់

ប្រជាជនកម្ពុជាទាំងមូល ជាពិសេស ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ ដូចជា *ក្រុមបុរសស្រឡាញ់បុរស និង ស្រីស្រស់ ក្រុមអ្នកធ្វើការនៅកន្លែងសេវាកម្សាន្តសប្បាយ និង អ្នកប្រើប្រាស់គ្រឿងញៀន ។* ហើយក្នុងចំណោមក្រុមទាំងនេះ ក្រុមបុរសស្រឡាញ់បុរស និង ស្រីស្រស់ ជាក្រុមដ៏គួរឱ្យព្រួយបារម្ភមួយ ដែលយើងទាំងអស់គ្នា ត្រូវតែយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លាផងដែរ ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី និង អង្គពិធីទាំងមូលជាទីមេត្រី!*

តាមរយៈការសិក្សា ប្រុសខ្មែរក្នុងឆ្នាំ ២០១០ របស់អង្គការ FHI360 ផ្តោតលើក្រុមគោលដៅបុរសស្រឡាញ់បុរស និង ស្រីស្រស់បានបង្ហាញថា អត្រាឆ្លងមេរោគអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និង ស្រីស្រស់ មានរហូតដល់ទៅ ២.១% ដែលនេះ បង្ហាញឱ្យឃើញថា ករណីនេះនៅតែជាបញ្ហាដ៏ធំរបស់ប្រទេសកម្ពុជាយើង ។ បើសិនជាយើងមិនមានវិធានការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពខ្ពស់នោះទេ បញ្ហាមេរោគអេដស៍ និង ជំងឺអេដស៍ នឹងវិលត្រឡប់មកក្នុងសង្គមកម្ពុជាយើងម្តងទៀតជាមិនខាន ហើយរលកទីពីរនេះពិតជាបង្កគ្រោះមហន្តរាយជាខ្លាំងដែលយើងមិនអាចទស្សន៍ទាយទុកបាន ។

អាស្រ័យហេតុនេះ យើងត្រូវធ្វើឱ្យមានចេរភាពនៃជោគជ័យ ដែលយើងទទួលបាននៅពេលនេះឲ្យបានបន្ថែមទៀត ដើម្បីឱ្យប្រទេសកម្ពុជាបន្តឈានទៅសំរេចឲ្យបាន នូវគោលដៅសូន្យបី នាឆ្នាំ២០២០ តាមរយៈការបន្ត នូវការទទួលខុសត្រូវ និង ចូលរួមទូលំទូលាយ និង ពហុវិស័យពីរាជរដ្ឋាភិបាល ស្ថាប័នឯកជន សង្គមស៊ីវិល ដៃគូអភិវឌ្ឍ បណ្តាញបុរសស្រឡាញ់បុរស និងស្រីស្រស់ និង ក្រុមប្អូនៗ ក្មួយៗដែលជាបុរសស្រឡាញ់បុរស និង ស្រីស្រស់នៅសហគមន៍ផ្ទាល់ ។ ផ្តើមចេញពីការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ថ្មីៗនេះគឺ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ កន្លងទៅ បានបើកកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយរបស់អាជ្ញាធរ ដែលក្នុងនោះ បានលើកឡើងនូវគោលការណ៍ ៧ ចំណុច ដើម្បីពង្រឹង និង ពង្រីកការអនុវត្តន៍ ការទប់ស្កាត់ ឲ្យកាន់តែមានប្រសិទ្ធភាព ។ ជាពិសេស គោលការណ៍ ៧ ចំណុច ត្រូវបានទទួលការគាំទ្រដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាលអាណត្តិទី ៥ ដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

គោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញ ដើម្បីប្រយុទ្ធនឹងជំងឺអេដស៍ ដែលមាន ៧ ចំណុចនោះ មានខ្លឹមសារដូចខាងក្រោម៖

១. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តសហការជាមួយបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិលផង ជំរុញ និង លើកទឹកចិត្តឲ្យមានការប្រើស្រោម អនាម័យឲ្យបាន ១០០% ដើម្បីសុវត្ថិភាពក្នុងការរួមភេទ ឲ្យរួចចាកការឆ្លងកាមរោគ និងមេរោគអេដស៍ ។

២. បញ្ចូលការប្រយុទ្ធនឹងជំងឺអេដស៍ និង សុខភាពមាតា ជាចំណុចបន្ថែមនៃគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ។

៣. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល និង ក្រសួង ស្ថាប័នពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិល ត្រូវសហការគ្នារៀបចំផែនទីបញ្ជាក់ពីភូមិសាស្រ្ត-ចំនួន-អ្នកផ្ទុកមេរោគអេដស៍-ក្រុមជនងាយរងគ្រោះមាន ៖ នារីបំរើសេវាកំសាន្ត-បុរសស្រឡាញ់បុរស-កុមារ កំព្រាដែលឪពុកម្តាយស្លាប់ដោយជំងឺអេដស៍-ជនចំណាកស្រុក ដែលផ្ទុកមេរោគអេដស៍ ចំនួន និង ទីកន្លែង មន្ទីរផ្តល់សេវាព្យាបាលជំងឺអេដស៍ ។

៤. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវចាត់វិធានការធ្វើឲ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំរាជធានី ខេត្ត ក្រុង ស្រុក ឃុំ/សង្កាត់ មានសកម្មភាពឡើងវិញ ។ ក្រសួងសុខា ភិបាល ត្រូវណែនាំដល់មន្ទីរសុខាភិបាលខេត្តនីមួយៗ ឲ្យសហការជិតស្និទ្ធជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខេត្ត ក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍ ។ គណៈកម្មធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តនីមួយៗ ត្រូវពង្រឹងលក្ខណៈជាដៃគូជាមួយអង្គការសង្គមស៊ីវិល ដែលកំពុងដំណើរការនៅក្នុងខេត្តរបស់ខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់ ។

៥. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និង បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវសហការគ្នា ដើម្បីអនុញ្ញាតឲ្យជនងាយរងគ្រោះដោយជំងឺអេដស៍ ដែលមានជាអាទិ៖ នារីបំរើសេវាកំសាន្ត បុរសស្រឡាញ់បុរស អ្នកញៀនគ្រឿងញៀនប្រើម្ជុល អាចទទួលបានសេវាព្យាបាលជំងឺអេដស៍បានយ៉ាងទូលំទូលាយ ។

៦. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងអប់រំ យុវជន និង កីឡា អង្គការយុវជន ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនការអប់រំដល់យុវជន-យុវនារី ឲ្យយល់ដឹងពីគ្រោះថ្នាក់នៃជំងឺអេដស៍ និង វិធីបង្ការ ការពារឲ្យបានទូលំទូលាយ ។

៧. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានតួនាទីដឹកនាំសំរបសំរួល និង តាមដានការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍ ដូចមានចែងក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ស្របតាមការចង្អុលបង្ហាញរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មការនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមុខនាទីដឹកនាំ និង ទទួលខុសត្រូវលើប្រសិទ្ធភាពនៃជំនួយសំរាប់ការឆ្លើយតបនឹងមេរោគអេដស៍ និង

ជំងឺអេដស៍ទូទាំងប្រទេស ។ ក្រសួងមន្ទីរពាក់ព័ន្ធ រាជធានី និង ខេត្ត ត្រូវសហការគ្នារៀបចំកម្មវិធីការងារប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីកែសម្រួលការប្រើប្រាស់ធនធាន ដែលបានទទួលពីគ្រប់មជ្ឈដ្ឋាន ឲ្យបានលទ្ធផលជាក់ស្តែង ប្រសិទ្ធភាព ប្រសិទ្ធិផល និង ឈានទៅធានានិរន្តរភាព ។

ដើម្បីធ្វើឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀតនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នឹងរៀបចំពិនិត្យឡើងវិញ នូវផែនការយុទ្ធសាស្ត្រជាតិលើកទី៣ និង បង្កើតជាផែនការសកម្មភាព ២០១៤ ។ ដោយយកគោលការណ៍ ៧ ចំណុច ជាគោលការណ៍ ដើម្បីឈានទៅទិសដៅយុទ្ធសាស្ត្រ សូន្យបីរបស់អង្គការសហប្រជាជាតិ នៅឆ្នាំ២០២០ ។ សំរាប់ក្រុមបុរសស្រឡាញ់បុរស និង ស្រីស្រស់ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំជាក្រុមការងារថ្នាក់ជាតិមួយ សំរាប់សម្របសម្រួលនិង តាមដានអនុវត្តការងារ ហើយដែលមួយរយៈពេលកន្លងទៅនេះ បានរៀបចំជាផែនការសកម្មភាពសំរាប់ឆ្នាំ ២០១៤ ដើម្បីធ្វើឲ្យការអនុវត្តន៍ទាំង ៧ចំណុចនោះ អនុវត្តកាន់តែមានប្រសិទ្ធភាពនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និង អង្គពិធីទាំងមូល ជាទីរាប់អាន!**

ក្នុងកិច្ចប្រជុំរយៈពេលមួយព្រឹកនេះ ខ្ញុំសង្ឃឹមថា យើងនឹងទទួលបានព័ត៌មានបន្ថែមទៀត ស្តីពីមូលហេតុ ឥរិយាបថ ការប្រព្រឹត្ត និង ការប្រឈមទៅនឹងការរីករាលដាលមេរោគអេដស៍ និង ជំងឺអេដស៍នៅកម្ពុជារបស់ក្រុមបុរសស្រឡាញ់បុរស និង ស្រីស្រស់ ហើយក៏រួមចំណែកផងដែរ ដល់ការកាត់បន្ថយការរើសអើងចំពោះក្រុមនេះ នៅក្នុងសង្គមរបស់យើង ។ ខ្ញុំសូមបញ្ជាក់ជូនផងដែរថា ការរើសអើង គឺជារនាំងមួយ ដែលអាចធ្វើឲ្យបទអន្តរាគមន៍បង្ការ និង ផ្តល់សេវាដល់ពួកគេ មិនបានទទួល ជោគជ័យតាមការរំពឹងទុក ។ ឆ្លៀតឱកាសដ៏មានតំលៃនេះ ក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមអំពាវនាវ បងប្អូនប្រជាពលរដ្ឋ អាជ្ញាធរដែនដី សូមកុំឲ្យមានការរើសអើង និង បន្តការសហការ ពិភាក្សាកាន់តែជិតស្និតថែមទៀត រវាងដៃគូទាំងអស់ និង អង្គការសង្គមស៊ីវិល ដើម្បីបញ្ចៀសបាន ពីការរីករាលដាលមេរោគអេដស៍ និង ជំងឺអេដស៍នៅកម្ពុជា ។

***ឯកឧត្តម លោកជំទាវ លោក.លោកស្រី និង ក្មួយៗជាទីរាប់អាន***

ជាទីបញ្ចប់ ខ្ញុំសូមធ្វើការអំពាវនាវ ដល់ស្ថាប័នរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ ស្ថាប័នឯកជន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ បណ្តាញបុរសស្រឡាញ់បុរស និង ស្រីស្រស់ និង ក្រុមប្អូនៗ ក្មួយៗ ដែលជាបុរសស្រឡាញ់បុរស និង ស្រីស្រស់នៅសហគមន៍ផ្ទាល់ បន្តចូលរួមយ៉ាងសកម្មបន្ថែមទៀត ក្នុងការប្រយុទ្ធប្រឆាំងមេរោគអេដស៍ និង ជំងឺអេដស៍ ជាពិសេសក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និង សូមអំពាវនាវដល់ម្ចាស់ជំនួយ បន្តផ្តល់ជំនួយទាំងថវិកា និង បច្ចេកទេស ដើម្បីឱ្យការអនុវត្តន៍ការងារ កាន់តែមានប្រសិទ្ធភាពខ្ពស់ ។

ខ្ញុំសូមប្រសិទ្ធពរជូនអង្គពិធីទាំងមូល នូវពុទ្ធពរទាំបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង សូមសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ជូនជាតិ មាតុភូមិនាឆ្នាំខាងមុខនេះ និង សូមប្រកាសបើកអង្គប្រជុំពីពេលនេះតទៅ។

**សូមអរគុណ**